## បញ្ឈប់ការជក់បារី

មិនត្រូវជក់បារីនៅមុន ឬក្រោយ
កំណើតទារករបស់អ្នក និងមិនត្រូវអនុញ្ញាតឲ្យ អ្នកដ
ទៃទៀតជក់បារីនៅជុំវិញទារករបស់អ្នកឡើយ។

## សីតុណ្ហភាពប្រចាំបន្ទប់

សូមស្លៀកពាក់ឲ្យទារករបស់អ្នកនៅក្នុង
សំលៀកបំពាក់គេងស្រាល និងត្រូវរក្សាបន្ទប់
នៅសីតុណ្ហភាពដែល
ងាយស្រួលសំរាប់មនុស្សពេញវ័យ។

## ហាមផ្ទៃទន់ល្មើយ

ទារកទាំងឡាយមិនត្រូវបានដាក់
ឲ្យគេងនៅលើគ្រែទឹក សាឡុង
ឬផ្ទៃទន់ល្មើយផ្សេងទៀតឡើយ។

## ពេលសំរាប់ក្រពះ

ត្រូវផ្តល់ "ពេលសំរាប់ក្រពះ" នៅពេលទារក
របស់អ្នកភ្ញាក់ពីគេង និងត្រូវបានមើលថែទាំ។

## ការប្រើប្រាស់ក្បាលដោះជ័រ

ការបំបោះកូនដោយទឹកដោះ គឺល្អបំផុត។
បន្ទាប់ពីការបំបៅកូនដោយទឹកដោះត្រូវបានធ្វើឡើង
ចូលផ្តល់ឲ្យទារករបស់អ្នកនូវក្បាលដោះជ័រមាន
អនាម័យមួយ អំឡុងពេលគេង។

## ការចាក់ថ្នាំបង្ការជំងឺ

ត្រូវប្រាកដថាទារករបស់អ្នកទទួលបាននូវ
ការពិនិត្យសុខភាព និងការចាក់ថ្នាំបង្ការទៀងទាត់។

## ហេតុអ្វី?

វាគឺសំរាប់ទារកទាំងឡាយ!

# តើការគេងដែលមានសុវត្ថិភាព មានលក្ខណៈដូចម្តេច?



ចំពោះព័ត៌មានស្តីពីការគេងដែលមានសុវត្ថិភាព
សំរាប់ទារក សូមមើលគេហទំព័ររបស់
ក្រសួងសុខាភិបាលរដ្ឋផេនស៊ីវ៉ាន់នៀ តាម
**www.health.state.pa.us/pasids**

pennsylvania
DEPARTMENT OF HEALTH

សូមថ្លែងអំណរគុណចំពោះ S.I.D.S. of PA/Cribs for Kids

HD0536P (Rev. 11/2017)

*កាត់បន្ថយ ហានិភ័យនៃ*

# រោគសញ្ញាការស្លាប់ភ្លាមៗរបស់ទារក (SIDS)

*និង*

# ការស្លាប់ដោយសារការថប់ដង្ហើមចៃដន្យ

*របស់ទារកអ្នកក្នុងអំឡុងពេលគេង*

# វាមានភាពងាយស្រួលដូចជា A, B, C

## A នៅម្នាក់ឯង

សូមរក្សា
កន្លែងគេងរបស់ទារកអ្នកនៅជិត
ប៉ុន្តែ ញែកដាច់ពីកន្លែងគេង
ដែលអ្នកផ្សេងទៀតគេង។
ទារករបស់អ្នកមិនគួរ
គេងនៅលើគ្រែ នៅលើ
កន្លែងទំរេត ឬនៅក្នុងកៅអី
ជាមួយដទៃទៀតឡើយ។

## B ខ្នង គឺល្អបំផុត

ទារករបស់អ្នកគួរ គេងផ្ងារ
នៅក្នុងគ្រែសំរាប់ទារក
ដែលបានយល់ស្របថាមានសុវត្ថិភាព
នៅលើពូកមិនស្រូតជារៀងរាល់ពេល
ដែលអ្នកដាក់ពួកគេចុះ ឲ្យគេង ដែលរួមបញ្ចូលទាំងការគេងពេលថ្ងៃផងដែរ។

## C នៅក្នុង គ្រែសំរាប់ទារក ដែលមិនរាយប៉ាយ

ត្រូវផ្លាស់ចេញនូវរាល់កម្រាលរលុង
វត្ថុធ្វើឲ្យសុខស្រួល
សំពត់ក្រាលកន្លែងគេង
ស្បែករោមសត្វចៀម
សត្វជាសំភារៈលេង
កម្រាលទ្រាប់គ្រែ និងខ្នើយចេញពី
គ្រែទារករបស់អ្នក។

## 1 មូលហេតុ នៃការស្លាប់

SIDS និង
ការស្លាប់ដោយសារការថប់ដង្ហើម
ដោយចៃដន្យ គឺជាមូលហេតុនាំមុខ
នៃការស្លាប់ចំពោះទារក អាយុ 1 ទៅ
12 ខែ។

## 2 អាយុ ប៉ុន្មានខែ

ទារកដែលមានអាយុពី 2 ទៅដល់ 4 ខែ
គឺស្ថិតនៅក្នុងហានិភ័យខ្ពស់
សំរាប់ SIDS និងការស្លាប់ដោយសារ
ការថប់ដង្ហើមចៃដន្យ។

## 3 ប្រាប់ អ្នកផ្សេងទៀត

ឲ្យចែករំលែកវិធីសាស្រ្ត
A, B, C, 1, 2, 3
យ៉ាងហោចណាស់ជាមួយមនុស្សឲ្យបាន
3 នាក់។ ការអប់រំ គឺជាគន្លឹះ
ចំពោះការរក្សាទារកឲ្យមានសុវត្ថិភាព។